**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៧០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់តាមតារាងពន្ធគយកម្ពុជា ឆ្នាំ២០២២ ជាធរមាន ដូចមានចែងក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២ .-**

ចំពោះមុខទំនិញចែងក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះដែលមានគោលដៅប្រើប្រាស់ពហុវិស័យ តម្រូវឱ្យចេញលិខិតអនុញ្ញាតនាំចេញ-នាំចូល តែពីក្រសួង-ស្ថាប័នមានសមត្ថកិច្ចណាមួយប៉ុណ្ណោះ ដែលមានចែងក្នុងឧបសម្ព័ន្ធ ឬក្រសួង-ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ស្របតាមគោលដៅនៃការប្រើប្រាស់ ឬកម្មវត្ថុអាជីវកម្ម។

**មាត្រា ៣ .-**

រាល់ពេលមានការធ្វើបច្ចុប្បន្នភាពប្រព័ន្ធស៊ីចង្វាក់ (លេខកូដទំនិញ) របស់អង្គការគយពិភពលោក (WCO) និងការធ្វើបច្ចុប្បន្នភាពនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់អាស៊ាន (AHTN) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញប្រកាសដើម្បីធ្វើបច្ចុប្បន្នភាពលេខកូដទំនិញក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៤ .-**

ការហាមឃាត់ ការតម្រូវឱ្យមានអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬលក្ខខណ្ឌនានា លើការនាំចេញ នាំចូល និងការដឹកជញ្ជូនឆ្លងកាត់ទំនិញ ត្រូវបានកំណត់ក្នុងបញ្ជីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ ក្នុងករណីមានតម្រូវការចាំបាច់ ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចលើកសំណើសុំកែសម្រួល រួមមាន ការបញ្ចូលបន្ថែមឬការដកចេញនូវមុខទំនិញពីបញ្ជីនេះ និងការកែសម្រួលប្រព្រឹត្តកម្មលើទំនិញនាំចេញ នាំចូល និងដឹកជញ្ជូនឆ្លងកាត់ជាដើម ទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ មុនដាក់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា ៥ .-**

ក្នុងករណីមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានចំណាត់ការបន្ទាន់ជាយថាហេតុ ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធអាចដាក់វិធានការជាបណ្តោះអាសន្នក្នុងការគ្រប់គ្រងការនាំចេញ នាំចូល និងការដឹកជញ្ជូនឆ្លងកាត់នៃមុខទំនិញដែលមានហានិភ័យខ្ពស់នោះ និងត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្ត។ ក្រសួងមានសមត្ថកិច្ច ត្រូវបញ្ជាក់កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ការអនុវត្ត ដោយមិនត្រូវលើសពី ៦ (ប្រាំមួយ) ខែឡើយ។ រយៈពេលនេះ អាចត្រូវបានពន្យារ ឬបញ្ចប់មុនពេលកំណត់ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃកម្រិតហានិភ័យ។

**មាត្រា ៦.-**

ក្រសួងមានសមត្ថកិច្ចត្រូវចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) ឱ្យបានពេញលេញ ដោយត្រូវជំរុញការចេញអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតនាំចេញ-នាំចូល ឬដឹកជញ្ជូនឆ្លងកាត់ជូនបុគ្គលស្នើសុំឱ្យបានក្នុងរង្វង់រយៈពេល ៣ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីពេលស្នើសុំ ប្រសិនបើសំណុំឯកសារមានលក្ខណៈត្រឹមត្រូវនិងគ្រប់គ្រាន់។

**មាត្រា ៧.-**

អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៤ តទៅ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**~~កន្លែងទទួល:~~**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ